# ថ្នាំ CIPROFLOXACIN ៖
# ថ្នាំអង់ទីប៊ីយោទិកសំរាប់អ្នកប៉ះពាល់អ្នកកើតជំងឺមេនីងហ្គោខូកខល

Ciprofloxacin គឺជាថ្នាំអង់ទីប៊ីយោទិកមួយដែលជួនកាលវេជ្ជបណ្ឌិតផ្តល់ទៅឲ្យអ្នកទាំងឡាយដែលប៉ះពាល់ជិតស្និទ្ធជាមួយនឹងអ្នកដែលបានកើតជំងឺមេនីងហ្គោខូកខល។ គោលបំណងនៃថ្នាំអង់ទីប៊ីយោទិកនេះគឺដើម្បីកំចាត់មេរោគមេនីងហ្គោខូកខល ដែលកំពុង"ស្ថិត"នៅក្នុងបំពង់កនៃអ្នកប៉ះពាល់មេរោគ ដើម្បីកុំឲ្យអ្នកទាំងនេះអាចចម្លងរោគនោះទៅកាន់អ្នកដទៃបន្តទៅទៀត។

ថ្នាំអង់ទីប៊ីយោទិកនេះមិនអាចព្យាបាលអ្នកដែលកំពុងកើតជំងឺនេះរួចហើយឡើយ ដូច្នេះលោកអ្នកនៅតែត្រូវប្រុងប្រយ័ត្នអំពីការកើតមានរោគសញ្ញា និងសញ្ញាទាំងឡាយនៃជំងឺមេនីងហ្គោខូកខល។

## ការណែនាំសំរាប់ការលេបថ្នាំ ciprofloxacin

- ថ្នាំ ciprofloxacin ជាថ្នាំលេបមានតែមួយកំរិត និងមានទំងន់ 500 មីលីក្រាម។
- លោកអ្នកគួរលេបថ្នាំគ្រាប់នេះទាំងមូលជាមួយនឹងទឹកមួយកែវពេញ។
- កុំលេបថ្នាំនេះ បើលោកអ្នកបានលេបថ្នាំបន្សាបអាស៊ីដឬថ្នាំបំបាត់បញ្ហារំលាយអាហារ ថ្នាំមានជាតិដែក ឬថ្នាំវីតាមីនខនិជក្នុងរង្វង់ពេល 4 ម៉ោងមុននេះ។

## លោកអ្នកមិនគួរលេបថ្នាំ ciprofloxacin ទេ បើលោកអ្នក៖

- ធ្លាប់មានប្រតិកម្មទំនាស់នឹងថ្នាំ ciprofloxacin;
- មានផ្ទៃពោះ ឬឲ្យកូនបៅដោះ;
- ជាក្មេងមានអាយុតិចជាង 12 ឆ្នាំ។

បើថ្នាំ ciprofloxacin មិនសមរម្យសំរាប់លោកអ្នកទេ លោកអ្នកនឹងត្រូវប្រើថ្នាំអង់ទីប៊ីយោទិកផ្សេងទៀតដើម្បីកំចាត់មេរោគមេនីងហ្គោខូកខល។

## ផលវិបាកបន្ទាប់បន្សំនៃថ្នាំ ciprofloxacin

- លោកអ្នកក៏អាចមានអារម្មណ៍អស់កម្លាំង ឬឈឺពោះផងដែរ ប៉ុន្តែជាធម្មតាការធ្វើទុក្ខទាំងនេះបាត់ទៅវិញយ៉ាងរហ័ស ហើយមិនមែនជាមូលហេតុធ្វើឲ្យបារម្ភទេ។
- ផលវិបាកបន្ទាប់បន្សំមិនធម្មតា**ខ្លាំង**មួយគឺប្រតិកម្មទំនាស់ដោយឡើងហើមមុខ។ ប្រតិកម្មនេះប្រហែលជាកើតឡើងយ៉ាងរហ័សក្រោយពីលេបថ្នាំនេះហើយ។ បើវាកើតឡើង លោកអ្នកគួរស្វែងរកជំនួយពេទ្យ**ភ្លាម**(ទៅជួបវេជ្ជបណ្ឌិត បើលោកអ្នកស្ថិតនៅក្នុងមន្ទីរពេទ្យ ឬទូរស័ព្ទទៅលេខ 000)។

## ប្រតិកម្មជាមួយថ្នាំពេទ្យផ្សេងទៀត

បើលោកអ្នកកំពុងលេបថ្នាំណាមួយផ្សេងទៀត លោកអ្នកគួរឆែកសាកសួរវេជ្ជបណ្ឌិតលោកអ្នកសិន មុនពេលលេបថ្នាំ ciprofloxacin ។ ការលេបថ្នាំ ciprofloxacin មិនបង្កគ្រោះថ្នាក់អ្វីទេ បើអ្នកលេបថ្នាំការពារកំណើត។

## ព័ត៌មានបន្ថែម - ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**

# ថ្នាំ RIFAMPICIN ៖

## ថ្នាំអង់ទីប៊ីយោទិកសំរាប់អ្នកប៉ះពាល់អ្នកកើតជំងឺមេនីងហ្គោខូកខល

Rifampicin គឺជាថ្នាំអង់ទីប៊ីយោទិកមួយដែលជួនកាលវេជ្ជបណ្ឌិតផ្តល់ទៅឲ្យអ្នកទាំងឡាយដែលប៉ះពាល់ជិតស្និទ្ធជាមួយនឹងអ្នកដែលបានកើតជំងឺមេនីងហ្គោខូកខល។ គោលបំណងនៃថ្នាំអង់ទីប៊ីយោទិកនេះគឺដើម្បីកំចាត់មេរោគមេនីងហ្គោខូកខលដែលកំពុង"ស្ថិត"នៅក្នុងបំពង់កនៃអ្នកប៉ះពាល់មេរោគ ដើម្បីកុំឲ្យអ្នកទាំងនេះអាចចម្លងរោគនោះទៅកាន់អ្នកដទៃបន្តទៅទៀត។

ថ្នាំអង់ទីប៊ីយោទិកនេះមិនអាចព្យាបាលអ្នកដែលកំពុងកើតជំងឺនេះរួចហើយឡើយ ដូច្នេះលោកអ្នកនៅតែត្រូវប្រុងប្រយ័ត្នអំពីការកើតមានរោគសញ្ញានិងសញ្ញាទាំងឡាយនៃជំងឺមេនីងហ្គោខូកខលផងដែរ។

## ការណែនាំឲ្យប្រើថ្នាំ **rifampicin**

- លោកអ្នកត្រូវលេបឬផឹកថ្នាំ rifampicin ចំនួនពីរដងក្នុងមួយថ្ងៃ រយៈពេលពីរថ្ងៃ (ត្រូវការចំនួនសរុបបួនកំរិត)។ ថ្នាំនេះមានជាគ្រាប់សំប៉ែត គ្រាប់មូលទ្រវែង ឬទឹកស៊ីរ៉ូ។
- លោកអ្នកគួរលេបឬផឹកថ្នាំ rifampicin ដោយគ្មានចំណីអាហារនៅក្នុងពោះ នៅពេលមួយម៉ោងនៅមុនពេលបរិភោគអាហារ ឬពីរម៉ោងក្រោយពីបរិភោគអាហារហើយ។

## លោកអ្នក<u>មិន</u>គួរប្រើថ្នាំ **rifampicin** ទេ បើលោកអ្នក៖

- មានប្រតិកម្មទំនាស់នឹងថ្នាំ rifampicin
- មានបញ្ហាថ្លើមដ៏ធ្ងន់ធ្ងរ (មានរួមទាំងខាន់លឿង);
- ញៀនសុរា; ឬ
- មានផ្ទៃពោះ។

បើថ្នាំ rifampicin មិនសមរម្យសំរាប់លោកអ្នកទេនោះ លោកអ្នកនឹងត្រូវប្រើថ្នាំអង់ទីប៊ីយោទិកផ្សេងទៀតដើម្បីកំចាត់មេរោគមេនីងហ្គោខូកខល។

## ផលវិបាកបន្ទាប់បន្សំនៃថ្នាំ **rifampicin**

- មនុស្សមួយចំនួនតូចមានអារម្មណ៍"មិនស្រួលខ្លួន" ក្រោយពីប្រើថ្នាំ rifampicin ហើយការឆ្អល់ពោះ ឈឺក្បាល និងវិលមុខអាចកើតមានឡើង។
- ថ្នាំ rifampicin អាចធ្វើឲ្យទឹកនោមនិងទឹកភ្នែកមានពណ៌ផ្កាឈូកលាយលឿងទុំ។ ហេតុការណ៍នេះមិនបង្កគ្រោះថ្នាក់ទេ ហើយបាត់ទៅវិញនៅពេលឈប់ប្រើថ្នាំនេះ។
- ថ្នាំ rifampicin អាចធ្វើឲ្យបន្ទះកែវពាក់នៅភ្នែក (contact lenses) ដែលទន់មានស្នាមប្រឡាក់ជាអចិន្ត្រៃយ៍ ហេតុនេះ លោកអ្នកគួរចៀសវាងការប្រើវានៅក្នុងអំឡុងពេលព្យាបាល។

## ប្រតិកម្មជាមួយថ្នាំពេទ្យផ្សេងទៀត

បើលោកអ្នកកំពុងប្រើថ្នាំចេញដោយវេជ្ជបញ្ជាដូចតទៅនេះ៖ ថ្នាំកុំឲ្យឈាមកក ដូចជាថ្នាំ warfarin, ថ្នាំស្តេរ៉ូអ៊ីដ, ថ្នាំមួយចំនួនសំរាប់ជំងឺបេះដូង, ថ្នាំទឹកនោមផ្អែម, ថ្នាំស្ពក់, ថ្នាំហឺត, មេថាដូន, ថ្នាំបន្សាបវីរុស, ថ្នាំសំរាលការលំបាកចិត្ត, និងថ្នាំ cyclosporin។ សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នកថា លោកអ្នកនឹងប្រើថ្នាំ rifampicin ដោយសារថាវេជ្ជបណ្ឌិតអាចត្រូវកែប្រែកំរិតថ្នាំពេទ្យឯទៀតរបស់លោកអ្នក។

ថ្នាំ rifampicin អាចកាត់បន្ថយប្រសិទ្ធភាពនៃថ្នាំលេបពន្យារកំណើត។ ស្ត្រីដែលលេបថ្នាំពន្យារកំណើតគួរលេបថ្នាំនេះតទៅទៀត ប៉ុន្តែកុំប្រើអំឡុងពេលដែលមិនប្រើថ្នាំឬលេបថ្នាំស្ករឡើយ នៅក្នុងពេលប្រើថ្នាំ rifampicin ព្រមទាំងរយៈពេលប្រាំពីរថ្ងៃក្រោយពីប្រើកំរិតចុងបង្អស់នៃថ្នាំ rifampicin ។ ស្ត្រីទាំងនោះគួរប្រើវិធីការពារកំណើតទប់ទល់បន្ថែមទៀត**ផងដែរ** ដូចជាប្រើស្រោមអនាម័យ នៅក្នុងពេលប្រើថ្នាំ rifampicin និងធ្វើដូចនេះរយៈពេលបួនអាទិត្យ ក្រោយពីកំរិតចុងបង្អស់នៃថ្នាំ rifampicin ។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**

## ថ្នាំ CEFTRIAXONE ៖
## ថ្នាំអង់ទីប៊ីយោទិកសំរាប់អ្នកប៉ះពាល់អ្នកកើតជំងឺមេនីងហ្គោខូកខល

Ceftriaxone គឺជាថ្នាំអង់ទីប៊ីយោទិកមួយដែលជួនកាលវេជ្ជបណ្ឌិតផ្តល់ទៅឲ្យអ្នកទាំងឡាយដែលប៉ះពាល់ជិតស្និទ្ធជាមួយនឹងអ្នកដែលបានកើតជំងឺមេនីងហ្គោខូកខល។ គោលបំណងនៃថ្នាំអង់ទីប៊ីយោទិកនេះគឺដើម្បីកំចាត់មេរោគមេនីងហ្គោខូកខល ដែលកំពុង“ស្ថិត”នៅក្នុងបំពង់កនៃអ្នកប៉ះពាល់មេរោគ ដើម្បីកុំឲ្យអ្នកទាំងនេះអាចចម្លងរោគនោះទៅកាន់អ្នកដទៃបន្តទៅទៀត។

ថ្នាំអង់ទីប៊ីយោទិកនេះមិនអាចព្យាបាលអ្នកដែលកំពុងកើតជំងឺនេះរួចហើយឡើយ ដូច្នេះលោកអ្នកនៅតែត្រូវប្រុងប្រយ័ត្នអំពីការកើតមានរោគសញ្ញានិងសញ្ញាទាំងឡាយនៃជំងឺមេនីងហ្គោខូកខលផងដែរ។

វេជ្ជបណ្ឌិតចាក់ថ្នាំ ceftriaxone មួយម្ជុលប៉ុណ្ណោះទៅក្នុងជាលិកាសាច់ដុំ ដូចជានៅនឹងភ្លៅ ឬគូទ។ ថ្នាំនេះមិនបង្កគ្រោះថ្នាក់ចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីឲ្យកូនបៅដោះឡើយ។

លោកអ្នក<u>មិន</u>គួរចាក់ថ្នាំ ceftriaxone ទេ បើលោកអ្នក៖

- មានប្រតិកម្មទំនាស់នឹងថ្នាំ ceftriaxone ឬថ្នាំអង់ទីប៊ីយោទិក cephalosporin ឯទៀត ឬ
- ធ្លាប់មានប្រតិកម្មទំនាស់ខ្លាំងឬភ្លាមនឹងថ្នាំអង់ទីប៊ីយោទិកប៉េនីស៊ីលីន។

## ផលវិបាកបន្ទាប់បន្សំនៃថ្នាំ ceftriaxone

- ផលវិបាកបន្ទាប់បន្សំនៃថ្នាំ ceftriaxone កំរកើតមានណាស់ ប៉ុន្តែផលវិបាកទាំងនេះមានរួមទាំងរោគជ្រាំងក្នុងមាត់ឬយោនី (ភ្នាសស្ពើងដែលឈឺឬរមាស់) រាករូស ក្អួត ឈឺក្បាល វិលមុខ ការផ្លាស់ប្តូររសជាតិ ចង្វាក់បេះដូងលឿនឬមិនប្រក្រតី។ លោកអ្នកគួរស្វែងរកជំនួយពេទ្យ បើលោកអ្នកមានការបារម្ភដោយសាររោគសញ្ញាណាមួយទាំងនេះ។
- ផលវិបាកបន្ទាប់បន្សំមួយដែលកំរកើតមានឡើងនោះគឺប្រតិកម្មទំនាស់ – បើលោកអ្នកហើមមុខ បំពង់កឡើងណែន លំបាកដកដង្ហើម មានរមាស់ខ្លាំងឬកន្ទួល លោកអ្នកគួរស្វែងរកជំនួយពេទ្យភ្លាម (ទូរស័ព្ទទៅលេខ 000)។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**

# ព័ត៌មានសំរាប់អ្នកប៉ះពាល់ជិតស្និទ្ធ អំពីថ្នាំអង់ទីប៊ីយោទិកកំចាត់មេរោគ និងថ្នាំបង្ការរោគ

ជំរាបមកដល់

នៅពេលថ្មីៗនេះ លោកអ្នកបានប៉ះពាល់ជិតស្និទ្ធជាមួយអ្នកដែលកើតជំងឺមេនីងហ្គោខូកខល។

ជំងឺមេនីងហ្គោខូកខលគឺបណ្តាលដោយបាក់តេរីមួយប្រភេទដែលមិនបង្កគ្រោះថ្នាក់អ្វីឡើយ និងស្ថិតនៅក្នុងច្រមុះនិងបំពង់ក របស់"មនុស្សដល់ទៅ 10%។ យ៉ាងណាមិញ នៅពេលម្តងម្កាលអ្នកផ្ទុកបាក់តេរីនេះអាចចម្លងវាទៅកាន់អ្នកដទៃដែលបានប៉ះពាល់ជិតស្និទ្ធនឹងខ្លួន។ មានតែអ្នកប៉ះពាល់ជិតស្និទ្ធនឹងអ្នកផ្ទុកបាក់តេរីមួយចំនួនតូចប៉ុណ្ណោះដែលកើតជំងឺមេនីងហ្គោខូកខល។ នៅពេល ឆ្លងបាក់តេរីនេះហើយ អ្នកប៉ះពាល់នោះអាចត្រូវការពេលដល់ទៅដប់ថ្ងៃដើម្បីកើតជំងឺនេះ។

បាក់តេរីទាំងនេះលំបាកឆ្លងទៅកាន់អ្នកដទៃ ហើយឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតតាមរយៈការប៉ះពាល់ជិតស្និទ្ធនិងយូរពេលតែប៉ុណ្ណោះ។ បាក់តេរីនេះកំរឆ្លងណាស់តាមការប៉ះពាល់នឹងទឹកមាត់នៅប៉ែកខាងមុខរបស់មាត់ ធ្មេញឬបបូរមាត់។

មានតែអ្នកដែលបានប៉ះពាល់ជិតស្និទ្ធណាស់នឹងអ្នកដែលគេសង្ស័យឬបញ្ជាក់ថាកើតជំងឺមេនីងហ្គោខូកខលប៉ុណ្ណោះ នឹងត្រូវការប្រើថ្នាំអង់ទីប៊ីយោទិកពិសេសដើម្បីកំចាត់មេរោគនេះពីទីជំរៅនៃបំពង់ក។ អ្នកទាំងនោះមានរួមទាំង៖

- អ្នកប៉ះពាល់ដែលនៅក្នុងផ្ទះជាមួយ និងអ្នកដទៃដែលបានស្នាក់នៅពេលមួយយប់នៅផ្ទះនោះ នៅក្នុងពេលប្រាំពីរថ្ងៃមុនពេលដែលអ្នកជំងឺនោះធ្លាក់ខ្លួនឈឺ  និង
- អ្នកប៉ះពាល់ជិតស្និទ្ធខ្លាំង ដូចជាសង្សារ ឬដៃគូរួមភេទ
- អ្នកទាំងឡាយដែលបានរួមថ្នាក់ជាមួយ នៅមណ្ឌលថែទាំកុមារ។

ដោយសារតែលោកអ្នកបានប៉ះពាល់ជិតស្និទ្ធខ្លាំងជាមួយអ្នកមានជំងឺនេះ លោកអ្នកអាចផ្ទុកបាក់តេរីមេនីងហ្គោខូកខល។ ដោយសារតែមូលហេតុនេះ លោកអ្នកគួរប្រើថ្នាំអង់ទីប៊ីយោទិកតាមកំរិតតូចមួយ។ ថ្នាំអង់ទីប៊ីយោទិកមានគោលបំណងបំបាត់បាក់តេរីដែលលោកអ្នកអាចមាន ដើម្បីបង្ការការឆ្លងសាយភាយតទៅទៀត។ ថ្នាំអង់ទីប៊ីយោទិកមិនព្យាបាលជំងឺមេនីងហ្គោខូកខលដែលជនណាមួយកំពុងកើតមានរួចហើយនោះទេ។ នៅក្នុងពេលកំពុងប្រើថ្នាំនេះ លោកអ្នកមិនចាំបាច់ចៀសវាងការប៉ះពាល់សមាជិកគ្រួសារនិងកុមារទេ ហើយលោកអ្នកក៏មិនចាំបាច់នៅដាច់តែឯងឬមិនទៅសាលារៀនឬកន្លែងការងារនោះឡើយ។

ដោយផ្អែកលើប្រភេទនៃបាក់តេរីមេនីងហ្គោខូកខល  ផ្នែកសុខភាពសាធារណៈអាចស្នើសុំឲ្យអ្នកនៅក្នុងផ្ទះជាមួយដែលប៉ះពាល់អ្នកកើតជំងឺមេនីងហ្គោខូកខល ចាក់ថ្នាំបង្ការរោគ។ ផ្នែកសុខភាពសាធារណៈនឹងជំរាបលោកអ្នក ថាតើការចាក់ថ្នាំនេះគឺជាការចាំបាច់ដែរឬទេ។

ជាការសំខាន់ក្នុងការស្វែងរកឱវាទពេទ្យជាបន្ទាន់ បើលោកអ្នកកើតមានរោគសញ្ញាណាមួយនៃជំងឺមេនីហ្គោខូកខល (រោគសញ្ញាទាំងនេះមានរៀបរាប់នៅខាងក្រោមនេះ) ឬបើលោកអ្នកធ្លាក់ខ្លួនឈឺ។ **សូមយកលិខិតនេះទៅជាមួយលោកអ្នក បើលោកអ្នកត្រូវទៅជួបវេជ្ជបណ្ឌិតលោកអ្នក ឬអគារសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ។**

សូមនិយាយអំពីជំងឺមេនីងហ្គោខូកខលប្រាប់អ្នកដែលជាធម្មតាលោកអ្នកចំណាយពេលច្រើននៅជាមួយ (ដូចជាគ្រួសារនិងមិត្តជិតស្និទរបស់លោកអ្នកជាដើម) ដើម្បីឲ្យអ្នកទាំងនោះដឹងផងដែរអំពីការស្វែងរកឱវាទពេទ្យ បើកើតមានរោគសញ្ញាទាំងពួង។

អ្នកឯទៀតដែលលោកអ្នកបានប៉ះពាល់នៅពេលថ្មីៗនេះ មិនចាំបាច់ប្រើថ្នាំអង់ទីប៊ីយោទិកទេ។

រោគសញ្ញានៃជំងឺមេនីងហ្គោខូកខលដែលត្រូវឃ្លាំមើល មានរួមទាំងការគួបផ្សំនៃ៖

- ការកើតមានគ្រុនក្តៅមួយរំពេច
- ឈឺសន្លាក់និងសាច់ដុំ
- ចង្អោរ និងក្អួត
- ឈឺក្បាល
- រឹងកញ្ចឹងក
- មិនចូលចិត្តពន្លឺភ្លឺខ្លាំង
- អស់កម្លាំង
- កន្ទួលឈឺដូចចាក់នឹងម្ជុលអាចកើតមាននៅលើស្បែកត្រង់កន្លែងណាមួយ ហើយកន្ទួលនេះអាចផ្លាស់ប្តូរយ៉ាងរហ័សទៅជាស្នាមជាំធំ។ ជាធម្មតាពេលសង្កត់តិចៗទៅលើស្បែក កន្ទួលនេះមិនបាត់ទៅវិញឡើយ។ ជួនកាលទៅ មិនកើតមានកន្ទួលទាល់តែសោះ។
- រោគសញ្ញាដើមដំបូងទាំងឡាយអាចមានរួមទាំងការឈឺចុកក្នុងជើង បាតដៃនិងបាតជើងឡើងត្រជាក់ ព្រមទាំងស្បែកមានពណ៌ចម្លែក។

**កុមារក្មេងៗ**អាចមានរោគសញ្ញាទូទៅជាង ដែលអាចមានរួមទាំងការមួយម៉ៅ វិលមុខឬលំបាកភ្ញាក់ពីដំណេក យំមានសម្លេងគ្រលួចឬយំថ្ងូរ ស្បែកស្លាំងនិងមានស្នាមជាំ និងមិនព្រមញ៉ាំចំណីអាហារ។

ទោះជាលោកអ្នកបានចាក់ថ្នាំបង្ការរោគមេនីងហ្គោខូកខលក្តី ក៏លោកអ្នកនៅតែត្រូវប្រុងប្រយ័ត្នអំពីរោគសញ្ញាទាំងឡាយដែរ ដោយសារតែថ្នាំបង្ការរោគនេះមិនការពារទល់នឹងប្រភេទមេនីងហ្គោខូកខលទាំងអស់ឡើយ។

ប័ណ្ណព័ត៌មានដែលមានដំណឹងបន្ថែមអំពីជំងឺមេនីងហ្គោខូកខល មាននៅតាមវិបសៃ៖
www.health.nsw.gov.au/factsheets/infectious/meningococcal.html

សូមទាក់ទងផ្នែកសុខភាពសាធារណៈ (Public Health Unit) បើលោកអ្នកមានសំណួរណាមួយថែមទៀត។
*បើលោកអ្នក ធ្លាក់ខ្លួនឈឺ សូមកុំទាក់ទងផ្នែកសុខភាពសាធារណៈ - សូមទៅជួបវេជ្ជបណ្ឌិតភ្លាម។*

ដោយសេចក្តីគោរពស្មោះស្ម័គ្រ

Director (នាយក)
Public Health Unit (ផ្នែកសុខភាពសាធារណៈ)

*ជំរាបមកដល់លោកវេជ្ជបណ្ឌិត*
*អ្នកនេះអាចជាអ្នកប៉ះពាល់ជិតស្និទ្ធនឹងអ្នកកើតជំងឺមេនីងហ្គោខូកខល។ បើអ្នកនេះមានជំងឺ សូមគិតពិចារណាអំពីជំងឺមេនីងហ្គោខូកខល នៅក្នុងការវិនិច្ឆ័យរកមើលរោគផ្សេងទៀតរបស់លោកវេជ្ជបណ្ឌិត ហើយរាយការណ៍ប្រាប់ផ្នែកសុខភាពសាធារណៈ តាមទូរស័ព្ទជាបន្ទាន់ បើសង្ស័យអំពីជំងឺមេនីងហ្គោខូកខល។*

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**

# ព័ត៌មានសំរាប់ <u>អ្នកប៉ះពាល់តាមក៏រិតទាប</u> (គ្មានប្រើថ្នាំអង់ទីប៊ីយោទិចទេ)

ជំរាបមកដល់

នៅពេលថ្មីៗនេះ លោកអ្នកបានប៉ះពាល់ជាមួយអ្នកដែលកើតជំងឺមេនីងហ្គោខូកខល។

ជំងឺមេនីងហ្គោខូកខលគឺបណ្តាលដោយបាក់តេរីមួយប្រភេទដែលគ្មានបង្កគ្រោះថ្នាក់ ហើយជាធម្មតាស្ថិតនៅក្នុងច្រមុះនិងបំពង់ករបស់មនុស្សដល់ទៅ 10%។ យ៉ាងណាមិញ នៅពេលម្តងម្កាលអ្នកផ្ទុកបាក់តេរីនេះអាចចម្លងវាទៅកាន់អ្នកដទៃដែលបានប៉ះពាល់ជិតស្និទ្ធនឹងខ្លួន។ មានតែអ្នកប៉ះពាល់ជិតស្និទ្ធនឹងអ្នកផ្ទុកបាក់តេរីមួយចំនួនតូចប៉ុណ្ណោះដែលកើតជំងឺមេនីងហ្គោខូកខល។ នៅពេលឆ្លងបាក់តេរីនេះហើយ អ្នកប៉ះពាល់នោះអាចត្រូវការពេលដល់ទៅដប់ថ្ងៃដើម្បីកើតជំងឺនេះ។

បាក់តេរីទាំងនេះលំបាកឆ្លងទៅកាន់អ្នកដទៃ ហើយឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតតាមរយៈការប៉ះពាល់ជិតស្និទ្ធនិងយូរពេលតែប៉ុណ្ណោះ។ បាក់តេរីនេះកំរឆ្លងណាសតាមការប៉ះពាល់នឹងទឹកមាត់នៅប៉ែកខាងមុខរបស់មាត់ ធ្មេញឬបបូរមាត់។

មានតែអ្នកដែលបានប៉ះពាល់ជិតស្និទ្ធ**ខ្លាំងណាស់**នឹងអ្នកដែលគេសង្ស័យឬបញ្ជាក់ថាកើតជំងឺមេនីងហ្គោខូកខលប៉ុណ្ណោះ នឹងត្រូវការប្រើថ្នាំអង់ទីប៊ីយោទិកពិសេសដើម្បីកំចាត់មេរោគនេះពីទីជំរៅនៃបំពង់ក។ អ្នកទាំងនោះមានរួមទាំងអ្នកប៉ះពាល់ដែលនៅក្នុងផ្ទះជាមួយអ្នកដែលបានស្នាក់នៅពេលមួយយប់នៅផ្ទះនោះ នៅក្នុងពេលប្រាំពីរថ្ងៃមុនពេលអ្នកជំងឺនោះធ្លាក់ខ្លួនឈឺ  និងអ្នកប៉ះពាល់ជិតស្និទ្ធខ្លាំង ដូចជាសង្សារឬដៃគូរួមភេទ និងអ្នកទាំងឡាយដែលបាននៅក្នុងថ្នាក់ជាមួយ នៅមណ្ឌលថែទាំកុមារ។

ដោយសារតែលោកអ្នកមិនបានប៉ះពាល់ជិតស្និទ្ធខ្លាំងជាមួយអ្នកមានជំងឺនេះ លោកអ្នក**មិន**ចាំបាច់ប្រើថ្នាំអង់ទីប៊ីយោទិកណាមួយឬចៀសវាងការប៉ះពាល់សមាជិកគ្រួសារឬកុមារទេ ហើយលោកអ្នកក៏មិនចាំបាច់នៅដាច់តែឯងឬមិនទៅសាលារៀនឬកន្លែងការងារនោះឡើយ។

ទោះជាគ្រោះថ្នាក់ក្នុងការកើតជំងឺនេះមានក៏រិតទាបណាស់ក្តី ក៏ជាការសំខាន់ក្នុងការស្វែងរកឱវាទពេទ្យជាបន្ទាន់ បើលោកអ្នកកើតមានរោគសញ្ញាណាមួយនៃជំងឺមេនីហ្គោខូកខល (រោគសញ្ញាទាំងនេះមានរៀបរាប់នៅខាងក្រោមនេះ) ឬបើលោកអ្នកធ្លាក់ខ្លួនឈឺ។ **សូមយកលិខិតនេះទៅជាមួយលោកអ្នក បើលោកអ្នកត្រូវទៅជួបវេជ្ជបណ្ឌិតលោកអ្នក ឬអគារសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ។**

សូមនិយាយអំពីជំងឺមេនីងហ្គោខូកខលប្រាប់អ្នកដែលជាធម្មតាលោកអ្នកចំណាយពេលច្រើននៅជាមួយ (ដូចជាគ្រួសារនិងមិត្តជិតស្និទ្ធរបស់លោកអ្នកជាដើម) ដើម្បីឲ្យអ្នកទាំងនោះដឹងផងដែរអំពីការស្វែងរកឱវាទពេទ្យ បើកើតមានរោគសញ្ញាទាំងពួង។

រោគសញ្ញានៃជំងឺមេនីងហ្គោខូកខលដែលត្រូវឃ្លាំមើល មានរួមទាំងការគួបផ្សំនៃ៖

- ការកើតមានគ្រុនក្តៅមួយរំពេច
- ឈឺសន្លាក់និងសាច់ដុំ
- ចង្អោរ និងក្អួត
- ឈឺក្បាល
- រឹងកញ្ចឹងក
- មិនចូលចិត្តពន្លឺភ្លឺខ្លាំង
- អស់កម្លាំង

- កន្ទួលឈឺដូចចាក់នឹងម្ជុលអាចកើតមាននៅលើស្បែកត្រង់កន្លែងណាមួយ ហើយកន្ទួលនេះអាចផ្លាស់ប្តូរយ៉ាងរហ័សទៅជាស្នាមជាំធំ។ ជាធម្មតាពេលសង្កត់តិចៗទៅលើស្បែក កន្ទួលនេះមិនបាត់ទៅវិញឡើយ។ ជួនកាលទៅ មិនកើតមានកន្ទួលទាល់តែសោះ។
- រោគសញ្ញាដើមដំបូងទាំងឡាយអាចមានរួមទាំងការឈឺចុកក្នុងជើង បាតដៃនិងបាតជើងឡើងត្រជាក់ ព្រមទាំងស្បែកមានពណ៌ចម្លែក។

**កុមារក្មេងៗ**អាចមានរោគសញ្ញាទូទៅជាងខាងលើ ដែលអាចមានរួមទាំងការមួយម៉ៅ វិលមុខឬលំបាកភ្ញាក់ពីដំណេក យំមានសម្លេងគ្រលួចឬយំថ្ងូរ ស្បែកស្លាំងនិងមានស្នាមជាំ និងមិនព្រមញុំាចំណីអាហារ។

ទោះជាលោកអ្នកបានចាក់ថ្នាំបង្ការរោគមេនីងហ្គោខូកខលក្តី ក៏លោកអ្នកនៅតែត្រូវឃ្លាំមើលរោគសញ្ញាទាំងឡាយដែរ ដោយសារតែថ្នាំបង្ការរោគនេះមិនការពារទល់នឹងប្រភេទមេនីងហ្គោខូកខលទាំងអស់ឡើយ។

ព័ត៌មានដែលមានដំណឹងបន្ថែមអំពីជំងឺមេនីងហ្គោខូកខល មាននៅតាមវិបសៃ៖
www.health.nsw.gov.au/factsheets/infectious/meningococcal.html

សូមទាក់ទងផ្នែកសុខភាពសាធារណៈ (Public Health Unit) បើលោកអ្នកមានសំណួរណាមួយថែមទៀត។
*បើលោកអ្នក ធ្លាក់ខ្លួនឈឺ សូមកុំទាក់ទងផ្នែកសុខភាពសាធារណៈ – សូមទៅជួបវេជ្ជបណ្ឌិតភ្លាម។*

ដោយសេចក្តីគោរពស្មោះស្ម័គ្រ

Director (នាយក)
Public Health Unit (ផ្នែកសុខភាពសាធារណៈ)

| |
|---|
| *ជំរាបមកដល់លោកវេជ្ជបណ្ឌិត* |
| *អ្នកនេះអាចជាអ្នកប៉ះពាល់ជិតស្និទ្ធនឹងអ្នកកើតជំងឺមេនីងហ្គោខូកខល។ បើអ្នកនេះមានជំងឺ សូមគិតពិចារណាអំពីជំងឺមេនីងហ្គោខូកខល នៅក្នុងការវិនិច្ឆ័យរកមើលរោគផ្សេងទៀតរបស់លោកវេជ្ជបណ្ឌិត ហើយរាយការណ៍ប្រាប់ផ្នែកសុខភាពសាធារណៈតាមទូរស័ព្ទជាបន្ទាន់ បើសង្ស័យអំពីជំងឺមេនីងហ្គោខូកខល។* |

## ព័ត៌មានបន្ថែម - ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW

**1300 066 055**

**www.health.nsw.gov.au**